អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D360/1/1/6

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៤៥)

**<u>អង្គបុរេជំនុំជម្រះ</u>**

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន**
**ចៅក្រម Olivier BEAUVALLET**
**ចៅក្រម ន៉ី ថុល**
**ចៅក្រម Kang Jin BAIK**
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: **ថ្ងៃទី២៦ ខែ តុលា ឆ្នាំ ២០១៧**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 10 / 2017
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ: កោសលុប**

**សេចក្តីសម្រេចលើពាក្យសុំរបស់ [redacted] សុំធ្វើអោយភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤**

---

**<u>សហព្រះរាជអាជ្ញា:</u>**
ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍:</u>**

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៤៥)

ឯកសារលេខ D360/1/1/6

ស្វ មូស្សេន្ទី
Susana TOMANOVIĆ
Neville SORAB

សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រ៊ីនណា
វ៉េន ពៅ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C.

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “ពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤” ដែលសហមេធាវីការពារក្តី [redacted] (“សហមេធាវី”) បានដាក់នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧ (“ពាក្យសុំ”)[1]។

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយចោទប្រកាន់ពីការចូលរួមរបស់អ្នកដាក់ពាក្យសុំ ទៅក្នុងអំពើព្រហ្មទណ្ឌ និងស្នើសុំឱ្យចោទប្រកាន់មកលើរូបគាត់[2]។

2. នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៧ សហមេធាវីបានដាក់ពាក្យសុំ ស្នើឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤[3] ដែលត្រូវបានទទួលយកដោយសហចៅក្រមអង្កេតអន្តរជាតិនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧[4]។

---

[1] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (“សំណុំរឿង ០០៤”) ពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D360/1/1/2 (“ពាក្យសុំ”) បានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧។ *សូមមើលផងដែរ* សំណុំរឿង ០០៤ សំណើបន្ទាន់សុំការអនុញ្ញាតដាក់ពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង តែមួយភាសា ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D360/1/1/1។

[2] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[3] សំណុំរឿង ០០៤ ពាក្យសុំរបស់ [redacted] ស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D360។

[4] សំណុំរឿង ០០៤ ដីកាសម្រេចលើពាក្យសុំរបស់ [redacted] ស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារ D360/1។



PRE-TRIAL CHAMBER CHAMBRE PR... E.C.C.C * C.E.T.C.

3. នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧ សហមេធាវីបានដាក់ពាក្យសុំរបស់ខ្លួននៅចំពោះមុខអង្គបុរេជំនុំជម្រះ។ នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់ខ្លួន[5] ហើយនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ សហមេធាវីបានដាក់ការឆ្លើយតបរបស់ខ្លួន[6]។

## II. ភាពទទួលយកបាន

4. សហមេធាវីលើកឡើងថា ពាក្យសុំអាចទទួលយកបានតាមវិធាន ៧៦(៤)[7]។ ពួកគេអះអាងថា ពាក្យសុំបានបង្ហាញហេតុផលគ្រប់គ្រាន់ ហើយមិនមែនគ្មានមូលដ្ឋានច្បាស់លាស់នោះទេ[8] ថា សម្ភារៈដែលរងការជំទាស់ត្រូវបានកំណត់អត្តសញ្ញាណយ៉ាងពេញលេញនៅក្នុងឧបសម្ព័ន្ធ[9] ហើយថា ពាក្យសុំមិនពាក់ព័ន្ធនឹងដីកាណាមួយដែលបច្ចុប្បន្នត្រូវប្តឹងឧទ្ធរណ៍នោះទេ[10]។ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានជំទាស់ទៅនឹងភាពទទួលយកបាននៃពាក្យសុំនេះទេ។

5. អង្គបុរេជំនុំជម្រះសូមរម្លឹកថា វិធាន ៧៦(២) នៃវិធានផ្ទៃក្នុង ចែងអំពីតួនាទីត្រួតពិនិត្យនៅក្នុងកិច្ចដំណើរការនីតិវិធីធ្វើមោឃភាពដល់ចៅក្រមស៊ើបអង្កេត ដែលត្រូវពិនិត្យមើលថា មាន "ករណី

---

[5] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង ពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D360/1/1/3 បានជូនដំណឹងនៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៧។

[6] សំណុំរឿង ០០៤ ការឆ្លើយតបរបស់ [redacted] ទៅនឹង ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង ពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D360/1/1/5 ("ការឆ្លើយតប") ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧។ *សូមមើលផង* សំណុំរឿង ០០៤ សំណើសុំការអនុញ្ញាតដើម្បីដាក់ការឆ្លើយតបរបស់ [redacted] ទៅនឹង ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង ពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤ តែមួយភាសា ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D360/1/1/4។

[7] ពាក្យសុំ កថាខណ្ឌ ១៦-២១។

[8] ពាក្យសុំ កថាខណ្ឌ ១៧-១៨។

[9] ពាក្យសុំ កថាខណ្ឌ ១៨។

[10] ពាក្យសុំ កថាខណ្ឌ ១៩។

01539820



អាចតវ៉ាបាន" ឬយ៉ាងណា ក្នុងន័យដែលថា តាមការវិភាគបឋម សំណើសុំឱ្យដោះស្រាយនោះមានទឡ្ហីករណ៍ដែលមានមូលហេតុ ឬយ៉ាងណា ដោយកំណត់អំពីកំហុសនីតិវិធី និងព្យសនកម្ម ហើយមិនមែនគ្មានមូលដ្ឋានច្បាស់លាស់ ឬយ៉ាងណា[11]។ វិធាន ៧៦(៤) នៃវិធានផ្ទៃក្នុងផ្តល់យុត្តាធិការដល់អង្គបុរេជំនុំជម្រះក្នុងសម្រេចពីភាពទទួលយកបាននៃពាក្យសុំធ្វើមោឃភាព ដែលអង្គជំនុំជម្រះអាចប្រកាសថាមិនអាចទទួលយកបាន នៅពេលដែលពាក្យសុំនោះពាក់ព័ន្ធនឹងដីកាដែលអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ គ្មានមូលដ្ឋានច្បាស់លាស់ ឬពុំមានមូលហេតុគ្រប់គ្រាន់[12]។

6. វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុងចែងថា៖

> "ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់ [...]"

7. បទប្បញ្ញត្តិនេះឆ្លុះបញ្ចាំងនូវមាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលចែងថា៖

> "ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់ [...]"

8. ហេតុនេះ វិធាន ៦០(១) នៃវិធានផ្ទៃក្នុងចែងថា "សហចៅក្រមស៊ើបអង្កេតអាចស្តាប់ចម្លើយពីជនណា ដែលខ្លួនយល់ឃើញថាមានសារៈប្រយោជន៍ក្នុងការសំដែងឱ្យឃើញការពិតដោយយោងទៅលើវិធាន ២៨"។ និយាយម្យ៉ាងទៀត វិធាននេះបញ្ជាក់អំពីឆន្ទានុសិទ្ធិទូលំទូលាយរបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងរបៀបប្រមូលភស្តុតាង តាមរយៈការស្តាប់ចម្លើយសាក្សីដោយខ្លួន

---

[11] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៨) សាលដីការបស់អង្គបុរេជំនុំជម្រះ ១) លើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ [redacted] សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D165/2/26 ("សាលដីកាលើសំណើចំនួនប្រាំបួន") កថាខណ្ឌ ៣៨-៤១។

[12] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០៤ (អបជ ៤០) សាលដីកាលើសំណើរបស់ [redacted] សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ Paolo STOCCHI ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ៧។

ឯង ដោយអ្នកស៊ើបអង្កេតដែលទទួលការចាត់តាំងទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ឬ ដោយកិច្ចស៊ើបសួរផ្សេងទៀតដែលមានប្រយោជន៍ក្នុងការស្វែងរកការពិត។

9. នៅក្នុងករណីនេះ អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហមេធាវីស្នើសុំធ្វើមោឃភាពសេចក្តីសម្រេច ដីកាសម្រេច និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការបំពេញកិច្ចស៊ើបសួរ ដែលដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤ ព្រមទាំងប្រតិចារឹកសវនាការពីសំណុំរឿង ០០២ ដែលពាក់ព័ន្ធ[13] ដោយជំទាស់ថា ការផ្ទេរភស្តុតាងជាសក្ខីកម្មពីកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ជាការរំលោភបំពានទៅលើវិធាន ៦០ នៃវិធានផ្ទៃក្នុង ហើយថា ភស្តុតាងរបស់សាក្សីគួរតែត្រូវបានប្រមូលដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងការស្តាប់ចម្លើយសាក្សី[14]។

10. ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះសង្កេតឃើញថា ពាក្យសុំពាក់ព័ន្ធនឹងការផ្ទេរភស្តុតាងដែលត្រូវបានទទួលយកតាមផ្លូវច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ដែលត្រូវបានបង្គាប់ដោយអនុលោមតាមវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង ហើយស្ថិតក្នុងឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបំពេញកិច្ចស៊ើបសួរដែលមានប្រយោជន៍ដល់ការស្វែងរកការពិត។ សហចៅក្រមស៊ើបអង្កេតពុំជាប់កាតព្វកិច្ចត្រូវតែស្តាប់ចម្លើយសាក្សី អនុលោមតាមវិធាន ៦០ នៃវិធានផ្ទៃក្នុង ហើយក៏មិនត្រូវបានតម្រូវឱ្យទទួលយកភស្តុតាងជាសក្ខីកម្មតាមរយៈការស្តាប់ចម្លើយសាក្សីសម្ងាត់ដែលធ្វើឡើងដោយខ្លួនឯងដែរ[15]។

11. ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ពាក្យសុំគ្មានមូលដ្ឋានច្បាស់លាស់ នៅក្នុងន័យដែលថា មានការបង្ហាញយ៉ាងប្រត្យក្ស ឬច្បាស់ក្រឡែតថា ពាក្យសុំនេះគ្មានអំណះអំណាងផ្នែកអង្គច្បាប់ទេ ហេតុដូច្នេះ សំណើបែបនេះគ្មានឱកាសនឹងត្រូវបានទទួលយកឡើយ[16]។ ហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចបដិសេធពាក្យសុំដោយសារមិនអាចទទួលយកបាន ហើយដោយពុំ

[13] ពាក្យសុំ កថាខណ្ឌ ២២។

[14] ពាក្យសុំ កថាខណ្ឌ ២៣-២៤។

[15] *ដូចយោងខាងលើ*។

[16] សាលដីកាលើសំណើចំនួនប្រាំបួន កថាខណ្ឌ ៤០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

មានទឡ្ហីករណ៍ អង្គជំនុំជម្រះសម្រេចថា សំណើនេះមិនគួរត្រូវបានបញ្ជូនមកក្នុងយុត្តាធិការរបស់ខ្លួនដើម្បីដោះស្រាយដូច្នេះឡើយ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**បដិសេធបណ្តឹងឧទ្ធរណ៍នេះ។**

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន Olivier BEAUVALLET ន៍យ ថុល Kang Jin BAIK ហួត វុទ្ធី**

*សេចក្តីសម្រេចលើពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពការដាក់សត្វីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ក្នុងសំណុំរឿង ០០៤*